# តួនាទី និងរចនាសម្ព័ន្ធពើងឥសី ភ្នំគូលែន

នៅរាជធានីមហេន្ទ្របព៌តភ្នំគូលែន ក្រៅពីចម្លាក់តាមប្រាសាទ ប្រព័ន្ធគ្រប់គ្រងទឹក និងកន្លែងយកថ្ម គឺភ្នំគូលែនមានចម្លាក់នៅលើផ្ទាំងថ្មធម្មជាតិ តាមពើង និងនៅតាមបាតស្ទឹងធម្មជាតិជាច្រើន។ **ពើងឥសី** គឺជារចនាសម្ព័ន្ធមួយដ៏សំខាន់សម្រាប់ការរៀបចំក្រុង ប្រព័ន្ធគ្រប់គ្រងទឹក ចម្លាក់លើផ្ទាំងថ្ម និងជំនឿសាសនានៅមហេន្ទ្របព៌ត។ តាមលោក Stern ឆ្នាំ ១៩៣៨ បានប្រទះឃើញចម្លាក់លើថ្មភ្នំ ដើងទម្រ ចម្លាក់ទេពកេទស្រី ចម្លាក់សត្វ និងចម្លាក់រឿងមួយចំនួនផ្សេងទៀត។[៧] ចម្លាក់នៅពើងឥសី និងស្រះទឹកនេះយើងអាចស្វែងយល់ពីការរៀបចំសម្រាប់ប្រភពទឹកធម្មជាតិភ្ជាប់ជាមួយសាសនា និងជំនឿទាក់ទងនឹងទឹកពិសិដ្ឋក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២។ តាមទីតាំងភូមិសាស្ត្រតំបន់ពើងឥសី ស្រះទឹក និងចម្លាក់ជុំវិញលើថ្មធម្មជាតិ គឺជាការរៀបចំសំណង់សំខាន់មួយសម្រាប់រាជធានីមហេន្ទ្របព៌ត។ តើពើងឥសី ចម្លាក់ជុំវិញ រូងថ្មមានទេពស្រីអម និងស្រះទឹកនេះមានទំនាក់ទំនងជាមួយគ្នាក្នុងន័យជាសាសនាបែបណា? តើហេតុអ្វីបានជាស្ថាបត្យកម្មខ្មែរ ឬព្រះមហាក្សត្រខ្មែរបង្កើតស្រះទឹកលាយជាមួយថ្មធម្មជាតិ និងចម្លាក់រូងថ្មជាមួយទេពស្រីអមសងខាងដើម្បីអ្វី? ការស្រាវជ្រាវបុរាណវិទ្យាផ្ទាល់ដី និងផែនទី LiDAR បញ្ជាក់ថាពើងឥសី ស្រះទឹក និងរូងថ្ម មានប្រភពទឹកធម្មជាតិហូរកាត់ និងមានរយៈកំពស់ខ្ពស់ជាងតំបន់បារាយណ៍ និងរាជវាំង។ ជាពិសេសតំបន់នេះក៏ជាប្រភពទឹកទាំងទឹកភ្លៀង និងទឹកជប់ពីក្រោមថ្មផងដែរ(រូបលេខ១-២)។ ចម្លាក់លើថ្មធម្មជាតិភាគច្រើននៅជុំវិញពើងឥសី និងស្រះទឹក មួយចំនួនមានប្រភពទឹកហូរកាត់ និងមួយចំនួនលិចទឹកនៅក្នុងរដូវវស្សា។ ចំណុចសំខាន់មួយទៀត នៅផ្នែកខាងលើស្រះទឹក និងពើងឥសីមានទួលមូលរត់ត្រង់ជាជួរ ដែលជាការរៀបសម្រាប់ពិធីសាសនាអ្វីមួយ ឬជាតំបន់ព្រាហ្មសម្រាប់គ្រប់គ្រងទឹក។ ចំណុចនេះត្រូវការទិន្នន័យបន្ថែម ដើម្បីបញ្ជាក់ពីតួនាទីទួលមូលរត់ជួរគ្នានេះបន្ថែមទៀត ត្បិតអីលោក Chevance (ក្រុមADF) បានធ្វើកំណាយម្តង

[៧] Stern 1938: 170-172

ហើយ តែមិនទាន់អាចសន្និដ្ឋានបានថាជាទីតាំងសម្រាប់អ្វីនោះទេ។ ដោយឡែកទួលរាង មូល ទំនប់ទប់ទឹក និងស្រះទឹក ឬបារាយណ៍លាយជាមួយប្រកពទឹកធម្មជាតិហូរកាត់បែប នេះ ព្រមទាំងស្ថិតនៅតំបន់ខ្ពស់ ក៏ប្រទះឃើញមាននៅព្លសានបុរៈ(សំបូរព្រៃគុក)។

ចម្លាក់នៅពើងឥសីមានតួនាទីសំខាន់ផ្សេងមួយទៀត ដើម្បីភ្ជាប់ជាមួយការរៀបចំប្រកព ទឹកពិសិដ្ឋ និងស្រះទឹកទាំងអស់នេះឡើង។ ចម្លាក់សំខាន់ៗទាំងនោះ មានចម្លាក់ព្រះវិស្ណុផ្ទំ លើនាគ (*Viṣṇu Anantaśāyin*) មានអាយុកាលស.វទី៩ដល់ទី១១គ.ស ចម្លាក់ព្រះវិស្ណុយកកំណើត ជាមនុស្សតឿ មានរៀបចំស្រះទឹកពីខឿនថ្មបាយក្រៀមភ្ជាប់ជាមួយថ្មធម្មជាតិ មានព្រះបាទ ព្រះសិរៈលើគោននិ្ទន សត្វអណ្តើក សត្វដំរី ក្បាលយក្ស ខ្លា ក្រពើ និងគ្រុឌ។

ចំណុចសំខាន់មួយទៀត យើងសង្កេតឃើញថា ពើងឥសីមានឆ្លាក់លើថ្មធម្មជាតិជារូប សត្វគ្រុឌ បំណែកនាគ អណ្តើក ក្រពើ បានឆ្លាក់នៅក្នុងទឹកស្រះជាមួយចម្លាក់ព្រះវិស្ណុផ្ទំលើ នាគ(រូបលេខ៣-៥)។ ពើងឥសីមានស្នាមកាត់ថ្ម ចាំងថ្ម ជញ្ជាំងផ្នែកខាងលើ និងខាងត្បូង និងស្រះដែលរៀបចំបន្សុតទឹកពិសិដ្ឋពីធម្មជាតិសម្រាប់យកធ្វើពិធីសាសនា។

ដូច្នេះការរៀបចំពើងឥសី មានប្រកពទឹកធម្មជាតិ មានស្រះទឹកភ្ជាប់ជាមួយថ្មភ្នំ ឬប្រកព ទឹកធម្មជាតិ មានចម្លាក់ព្រះវិស្ណុផ្ទំលើនាគផុសចេញកណ្តាលស្រះ និងចម្លាក់សត្វឬទេពមួយ ចំនួនដែលឆ្លាក់មិនទាន់រួច ឬក៏ជាបំណែកនៅក្នុងបាតស្រះ ប្រហែលជាការរៀបចំជាយ័ន្តឬ ពិធីសម្រាប់សាសនាតាមបែបខ្មែរលាយឥណ្ឌា ដែលទាក់ទងនឹងការបង្កើតលោកថ្មី រាជធានី ថ្មី និងកសាងសំណង់ថ្មីៗ(រូបលេខ៦-៧)។ តើការរៀបចំចម្លាក់នៅពើងឥសី និងស្រះទឹកមាន ទំនាក់ទំនងអ្វីខ្លះជាមួយប្រាសាទរោងចិន បារាយណ៍ថ្នល់ម្រេច និងរាជវាំង? តាមការរៀបចំ ពើងឥសីនិងស្រះទឹកនេះឡើង គឺជាទំនៀមសាសនាខ្មែរលាយជាមួយឥណ្ឌា ដែលបន្តពី សម័យមុនអង្គរ រហូតប្រទះឃើញមានការរៀបចំដូចគ្នានឹងពើងឥសីដែរ នៅត្រពាំងខ្នាររាជ ជានីកោះកេររបស់ព្រះបាទជ័យវរ្ម័នទី៤ និងសម័យក្រោយៗទៀតជាបន្តបន្ទាប់៕




រូបលេខ១៖ ផែនទី និងប្លង់បង្ហាញទីតាំងពើងឥសី ទួលរាង មូលរត់ជាក្រឡាចត្រង្គនៅខាងលិច នៅមហេន្ទ្របព៌ត (ភ្នំគូលែន)




រូបលេខ២៖ ប្លង់បង្ហាញទីតាំងពើងឥសី និងទីតាំងចម្លាក់ នៅមហេន្ទ្របព៌ត(Chevance 2013 ក្រុមADF)







រូបលេខ៣-៥៖ ចម្លាក់ដំរី ក្រពើ(EFEO) ត្រីវិក្រាម និងចម្លាក់សត្វផ្សេងៗទៀតនៅបាតស្រះពើងឥសី





រូបលេខ៦-៧៖ ស្រះទឹក ចម្លាក់ព្រះវិស្ណុផ្ទំលើនាគ អណ្តើក សត្វផ្សេងៗនៅបាតស្រះ និងរូងថ្ម នៅពើងឥសី(រូបថតដោយសាក្កដា ២០២១)



អត្ថបទដោយ៖ ថូ ថុន




រូបលេខ៨៖ ផែនទីបង្ហាញទីតាំងរាជវាំង(បន្ទាយ) និងចំណុចប្រសព្វប្រឡាយឬស្ទឹងរត់ចំអ័ក្សព្រះរាជវាំង

## សង្ខេប

អត្ថបទនេះចង់បង្ហាញពីតួនាទី និងរចនាសម្ព័ន្ធស្រះឬពើងឥសីជាប្រភពទឹក ដែលបុរាណលោកច្នៃឱ្យទៅជាកន្លែងគោរពបូជា មានន័យថា (ទេពអាចលេចតាមបែបធម្មជាតិជាដើមចមដំបូងនៃថាមពល និងជាចំនុចតំបូង ឬជាទីតាំងសំខាន់ជាងគេនៅអំឡុងពេលលោកយាងចុះមកលើផែនដី)។ ដូច្នេះហើយនៅពេលកសាងក្រុង ចាស់បុរាណលោកតែងកំណត់ និងច្នៃទីតាំងធម្មជាតិណាមួយជាពិសេសប្រភពទឹកជ្រោះ ឬស្ទឹង ឲ្យក្លាយជាទីតាំងរបស់ទេព ក្នុងន័យបញ្ជាក់ពីប្រភពថាមពល និងប្រាថ្នាឲ្យក្រុងនោះរីកចំរើន ប្រកបដោយភោគផលតាមគន្ធងរបស់ទេព។ សេចក្ដីសន្និដ្ឋានបែបនេះ យើងអាចពន្យល់តាមភស្តុតាងនៅតាមក្រុងបុរាណសំខាន់ៗមួយចំនួនដូចជា រាជធានីព្សាបុរ:(សំបូរព្រៃគុក) កោះកេរ និងយសោធរបុរ:(តំបន់អង្គរ)ជាដើម។ល។ ដោយឡែកករណីភ្នំគូលែន(ពើងឥសី) ជា

ឧទាហរណ៍ល្អមួយ ហើយចំណុចដែលប្លែក ទីតាំងនេះមានជំនឿដ៏កម្រមួយ ពោលគឺ ទាក់ទងនឹងទេពស្រីពីរអង្គ គឺតំណាងឲ្យទន្លេគង្គា និងទន្លេយមុនា ដែលឆ្លាក់នៅអមសងខាងគុហាថ្មែពីថ្មធម្មជាតិ(ឈុំ ម៉េងហុង, ២០២១)។ ចំពោះជំនឿចំណុចប្រសព្វរបស់ទន្លេទាំង២ ជាទីតាំងសំខាន់មួយដែលបណ្តាលអោយអ្នកគោរពអាចជួបជាមួយនឹងទេព ឬអាចឡើងឋានសួគ៌បាន តាមអំណាចនៃទឹកពិសិទ្ធរបស់ទន្លេទាំងពីរជាអ្នកលាងជម្រុះបាបកម្មទាំង ដែលជាប់នឹងខ្លួនមនុស្ស។ ហេតុដូច្នេះហើយ ព្រះមហាក្សត្រខ្មែរ និងព្រាហ្ម តែងតែស្វែងរកប្រភពទឹកធម្មជាតិ ដែលហូរប្រសព្វគ្នាយ៉ាងហោចណាស់២ទៅ៤ ដើម្បីស្ថាបនារាជធានីឬរាជវាំង។ ការរៀបចំក្រុង មានប្រភពទឹកធម្មជាតិប្រសព្វគ្នា(តំណាងអោយទន្លេពិសិដ្ឋទាំង២ឬ៤) វត់ត្រង់ចំអ័ក្សរាជវាំងឬក្រុង ដូចជារាជធានីវ្លៀសាបុរៈសំបូរព្រៃគុក រាជធានីមហេន្ទ្របព៌ត(ភ្នំគូលែន) យសោធរបុរៈ*(រូបលេខ៨)*។ល។ ដោយឡែកការរៀបចំរាជវាំង ឬក្រុងតាមជំនឿខ្មែរលាយជាមួយឥណ្ឌាបែបនេះ គឺប្រហែលមានរៀបចំតាំងពីមុនរាជធានីវ្លៀសាបុរៈសំបូរព្រៃគុកមកម្លេះ ដូចជារាជធានីនៅអង្គរបុរី និងវត្តភូ។ ត្រង់ចំណុចនេះយើងត្រូវការកស្តុតាងមួយចំនួនទៀត ដើម្បីបញ្ជាក់ពីការរៀបចំក្រុងសម័យហ្វូណនទៅតាមចំណុចប្រសព្វគ្នារបស់ទន្លេធម្មជាតិ។

ត្រង់ចំណុចនេះ ពើងឥសីមានតួនាទី និងគំរូសំខាន់ផ្សេងទៀតដូចជា ការរៀបចំស្រះទឹកពើងឥសីភ្ជាប់ជាមួយប្រភពទឹកធម្មជាតិ ដែលឃើញបន្តនៅត្រពាំងខ្នារកោះកេរសម័យក្រោយមកទៀត។ ពើងឥសីឬស្រះឥសីនេះ គឺជាការចាប់ផ្តើមរៀបចំកន្លែងទឹកពិសិដ្ឋ និងការឆ្លាក់បង្ហាញទេព និងចម្លាក់សត្វសំខាន់ៗក្នុងន័យជាការបញ្ចុះយន្ត ដែលយើងឃើញមានប្រើប្រាស់បន្តសម្រាប់បារាយធំៗ និងស្រះទឹកសំខាន់ៗសម្រាប់សាសនា។ ឧទាហរណ៍ដូចជាការឆ្លាក់ចម្លាក់ព្រះវិស្ណុផ្ទុំនៅចំកណ្តាលស្រះឬបារាយ ការឆ្លាក់ព្រះកេស ចម្លាក់អណ្តើកចម្លាក់ក្រពើ ចម្លាក់នាគ និងសត្វផ្សេងៗ គឺមិនអោយមានរូបរាងពេញលេញនោះទេ។ ដូច្នេះក្នុងន័យបង្កើតថ្មី និងកសាងអ្វីដែលថ្មី គឺបង្ហាញការឆ្លាក់លើថ្មធម្មជាតិទម្រង់ជាបែកបាក់ ឬ

កំពុងតែធ្លាក់មិនទាន់រួចក្នុងន័យជំនឿសាសនាប៉ុណ្ណោះ។ ទាំងអស់នេះយើងប្រទះឃើញបន្ដជាភស្តុតាងមានការបញ្ចុះចម្លាក់នាគ រូបគុវេរ និងចម្លាក់ផ្សេងៗមួយចំនួន តម្រៀបបញ្ចុះតាមទិស នៅកណ្ដាលស្រះស្រង់ដូច្នេះដែរ។

## ឯកសារយោង

1- Chevance Jean Baptiste (2013).

Poeng Tbal et Peong Eisei, ermitages angkoriens meconnus du Phnom Kulen, ADF, *Aseanie 32*, P.11-76.

2- Stern Phillippe (1938).

Travaux Executes au Phnom Kule, BEFEO, Volume 38, Numero 1, p.170-172, (http:/www.persee.fr)